ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និងឈ្មោះសំណុំរឿង : ១៤៨/០៧ — ចាយ ហឺ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ហែម ហួណារិទ្ធិ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ចាយ ហឺ**

អាសយដ្ឋាន : ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : គ្មាន ទូរសារលេខ : គ្មាន

តំណាងភាគីនិយោជក : អវត្តមាន

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ : **សម្ព័ន្ធសហជីព-សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ**

អាស័យដ្ឋាន : ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៣៩៦ ០៦៩ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត :

១-លោក អ៊ុំ វិសាល អគ្គលេខាធិការរង C.CAWDU

២-លោក ម៉ាត់ ស៊ុបពីអ៊ី ប្រធានសហជីពប្រចាំរោងចក្រ ប៉ាយ ហឺ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-សុំឱ្យក្រុមហ៊ុនទទួលយកបេក្ខជនចំនួន ៨នាក់ មានដូចជា ឈ្មោះ ១-លោក ម៉ាត់ ស៊ុបពីអ៊ី ២-អ្នកស្រី សឿន វណ្ណារី ៣-លោកស្រី ចាន់ សាន់ ៤-កញ្ញា វ៉ែន លក្ខណា ៥-កញ្ញា ជិន ស្រីនាង ៦-កញ្ញា ហេត ម៉ារី ៧-លោកស្រី ឆាន ហៃ ៨-លោកស្រី ស៊ុន សោភ័ណ្ឌ ចូលធ្វើការកន្លែងដើមវិញ ដោយរក្សាប្រាក់ឈ្នួល និងកន្លែងការងារនៅដដែល ហើយកុំឱ្យមានការគំរាមកំហែង ឬបង្កការលំបាកផ្សេងៗ ។

២-សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ខែគោល ៥០ ដុល្លា ក្នុងមួយខែទៅតាមច្បាប់ស្តីពីការងារ ។

៣-សុំឱ្យក្រុមហ៊ុនគិតលុយធ្វើការថ្ងៃអាទិត្យ លុយថែមម៉ោង និងលុយថ្ងៃបុណ្យ ឱ្យបានត្រឹមត្រូវទៅតាមច្បាប់ស្តីពីការងារ ។

៤-សុំឱ្យក្រុមហ៊ុនបញ្ឈប់ការគំរាមគំហែងកម្មករនៅពេលកម្មករមិនថែមម៉ោង ។

៥-សុំឱ្យក្រុមហ៊ុនសំរួលដល់ការសុំច្បាប់ដល់កម្មករនៅពេលមានធុរៈចាំបាច់ ។

៦-សុំឱ្យក្រុមហ៊ុនបើកប្រាក់ថ្លៃបាយចំនួន៨០០រៀល នៅពេលកម្មករ និយោជិតធ្វើការថែមម៉ោង ។

៧-សុំឱ្យក្រុមហ៊ុនសង់ទារកដ្ឋាន និងរៀបចំឱ្យមានបន្ទប់សំរាប់ព្យាបាលអ្នកជំងឺ និងមានថ្នាំពេទ្យឱ្យគ្រប់គ្រាន់ ។

៨-សុំឱ្យក្រុមហ៊ុនចេញវិក័យបត្របើកប្រាក់ខែឱ្យបានត្រឹមត្រូវតាមច្បាប់ ។

៩-សុំឱ្យក្រុមហ៊ុនទទួលខុសត្រូវលើគ្រោះថ្នាក់ការងារ ។

១០-សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះចេញមុនម៉ោង ៥នាទី ឬ១០នាទី ។

១១-សុំឱ្យក្រុមហ៊ុនធ្វើការថែមម៉ោង ផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។

១២-ត្រូវផ្តល់ប្រាក់ឈ្នួលដល់ស្ត្រី ៥០ ភាគរយ ព្រមទាំងប្រាក់បន្ទាប់បន្សំមុនការឈប់សំរាកទៅលំហែមាតុភាពក្នុងរយៈពេល៩០ថ្ងៃ ។

ដោយឡែកភាគីក្រុមហ៊ុនមិនបានអញ្ជើញមកចូលរួមផ្សះផ្សាតាមការកំណត់ ដោយអវត្តមាន ដោយគ្មានមូលហេតុ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាស លេខ ០៩៩ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៧៦/០៧ កកបវ./ ប្រកចុះថ្ងៃ ទី១០ ខែឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួមដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១៣៨០ ក.ប./អក/វក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :**

សវនាការលើកទី១: ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ (វេលាម៉ោង ១៤:០០នាទី) ។

(ភាគីកម្មករនិយោជិតសុំលើកពេលសវនាការ)

សវនាការលើកទី២: ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ (វេលាម៉ោង ១៤:០០នាទី ១៦:០០នាទី) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៧ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ ប៉ុន្តែមិនបានទទួលលទ្ធផលសះជានឹងគ្នា លើចំណុចណាមួយទេ លើការទាមទារចំនួន ១២ចំណុចដោយសារភាគីនិយោជកមិនសហការ និងមិនចូលរួមដោះស្រាយ ។ ចំណុចមិនសះជាចំនួន ១២ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និង ភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និង ធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១២ចំណុចនេះ លើកទី១ នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៨ វេលាម៉ោង ១៤:០០នាទី ។ ភាគីកម្មករនិយោជិតទទួលលិខិតអញ្ជើញមកសវនាការ ប៉ុន្តែ ស្នើសុំលើកពេលសវនាការដោយមូលហេតុ ថ្នាក់ដឹកនាំសហជីពជាប់រវល់ចូលរួមសិក្ខាសាលានៅខេត្តកំពង់ចាម ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលអប់រំច្បាប់ ដើម្បីសហគមន៍ ។ ចំណែកភាគី និយោជកវិញបដិសេធមិនទទួលលិខិតអញ្ជើញសវនាការការទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឯកភាពស្នើសុំភាគីកម្មករនិយោជិតហើយបានកំណត់ពេលសវនាការលើកទី២ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ វេលាម៉ោង ១៤:០០នាទី ។ ភាគីកម្មករនិយោជិតទទួលលិខិតអញ្ជើញមកសវនាការ ហើយបានចូលរួមសវនាការ ។ ចំណែកភាគីនិយោជកវិញបដិសេធមិនទទួលលិខិតអញ្ជើញចូលសវនា ការជាលើកទី២ ហើយក៏មិនបានមកចូលរួមសវនាការដែរ ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបើកសវនាការដោយអវត្តមានរបស់ភាគីនិយោជក ។ នៅក្នុងសវនាការភាគីកម្មករនិយោជិតបានឯកភាពដកការទាមទារចំនួន ១១ចំណុច ហើយបានស្នើសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែលើចំណុចទី១ ប៉ុណ្ណោះ ។ ហេតុនេះហើយក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើចំណុចវិវាទទី១ ដោយផ្អែកលើភស្តុតាង និងការឆ្លើយបំភ្លឺរបស់ភាគីកម្មករនិយោជិតនៅក្នុងសវនាការ ដូចខាងក្រោម៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :** គ្មាន

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១-លិខិតលេខ០០៣/០៨ ស.ប.ក.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការស្នើសុំលើកពេលសវនាការ

២-សារណាសង្ខេបស្តីពីសកម្មភាពសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ប៉ាយ ហ៊ី ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០០៨ ។

៣-លិខិតលេខ ០៦៥/០៧ ស.ប.ក.ក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការជូនដំណឹងពីលទ្ធផលនៃការបោះឆ្នោតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ប៉ាយ ហ៊ី ។

៤-លិខិតលេខ ០៩៦/០៧ ស.ប.ក.ក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការជូនដំណឹងពីការរៀបចំបោះឆ្នោតបង្កើតសហជីពថ្មីប្រចាំរោងចក្រ ប៉ាយ ហឺ ។

៥-វិញ្ញាបនប័ត្រចុះបញ្ជិកាលេខ ១២១១ កប/វក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៧ ។

៦-កំណត់ហេតុស្តីពីការបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ប៉ាយ ហឺ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៧ ។

៧-លិខិតលេខ ០២៩/០៧ ស.ប.ក.ក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការជួយដោះស្រាយបញ្ហាលក្ខខណ្ឌការងារ និងការរើសអើងសហជីពនៅរោងចក្រ ប៉ាយ ហឺ ។

៨-ស្នាមមេដៃរបស់កម្មករនិយោជិតនៃរោងចក្រ ប៉ាយ ហឺ ស្តីពីការដោះស្រាយបញ្ហាលក្ខខណ្ឌការងារ និងការរើសអើងសហជីពនៅរោងចក្រ ប៉ាយ ហឺ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ប៉ាយ ហឺ លេខ ២៤/០៨ កប ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨។

២-កំណត់ហេតុផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ប៉ាយ ហឺ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១-លិខិតអញ្ជើញនាយកក្រុមហ៊ុន ចូលរួមសវនាការលើកទី១ លេខ ០០៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការលើកទី១ លេខ ០០៩ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨។

៣-លិខិតអញ្ជើញនាយកក្រុមហ៊ុន ចូលរួមសវនាការលើកទី២ លេខ ០៦៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨។

៤-លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការលើកទី២ លេខ ០៦៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨។

## ការរកឃើញអង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលភាគីបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

- ក្រុមហ៊ុន ប៉ាយ ហ៊ី មានជួលកម្មករនិយោជិតចំនួនប្រហែល ៥០០ នាក់ ។
- តាមការអះអាងរបស លោក ម៉ាត់ ស៊ុបពិអ៊ី ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន ប៉ាយហ៊ី ដែលជាជាដើមបណ្តឹង នៅក្នុងរឿងនេះបញ្ជាក់ថា សហជីពនេះបានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកានៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៧ ។
- តាមការអះអាងរបស់ប្រធានសហជីព លោក ម៉ាត់ ស៊ុបពិអ៊ី បញ្ជាក់ថាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ប៉ាយ ហ៊ី មានសមាជិកជាង ១០០នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ៥០០នាក់ ។
- លោក ម៉ាត់ ស៊ុបពិអ៊ី ប្រធានសហជីព បញ្ជាក់ថា នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានប្រគល់លិខិតជូនដំណឹងអំពីការរៀបចំបោះឆ្នោតបង្កើតសហជីពថ្មីលេខ ០៥៦/០៧ ស.ប.ក.ក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ ទៅឱ្យនិយោជក ហើយសន្តិសុខរបស់ក្រុមហ៊ុនជាអ្នកចុះហត្ថលេខាទទួលយក ។ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៧ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានរៀបចំបោះឆ្នោតតាមនីតិវិធី ។ ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាបានជូនដំណឹងទៅក្រុមហ៊ុនអំពីលទ្ធផលនៃការបោះឆ្នោត ។

**<u>ចំណុចបញ្ហាវិវាទទី១: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកបេក្ខជនឈរឈ្មោះថ្នាក់ដឹកនាំសហជីពចំនួន ០៨នាក់ចូលធ្វើការវិញគឺ ១- លោក ម៉ាត់ ស៊ុបពីអី ២- អ្នកស្រី សឿន វណ្ណារី ៣-លោកស្រី ចាន់ សាន់ ៤-កញ្ញា វ៉ែន លក្ខណា ៥-កញ្ញា ជិន ស្រីនាង ៦-កញ្ញា ហេត ម៉ារី ៧-លោកស្រី នាន ហៃ ៨-លោកស្រី ស៊ុន សោភណ្ឌ័</u>**

- តាមការអះអាងរបស់ប្រធានសហជីព ក្រុមហ៊ុនបានបញ្ឈប់កម្មករនិយោជិតទាំង ០៨នាក់នេះជាពីរដំណាក់កាលគឺ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ និងនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ ។ មូលហេតុនៃការបញ្ឈប់កម្មករនិយោជិតចំនួន ០៨នាក់ មកពីកម្មករនិយោជិតទាំងអស់នេះរួមគ្នាបង្កើតសហជីព ។ ប្រធានសហជីពបញ្ជាក់ថា កម្មករនិយោជិតទាំងអស់នេះមិនដែលបានទទួលការព្រមានម្តងណាពីក្រុមហ៊ុនទេ ។ ប្រធានសហជីពបញ្ជាក់ថា ក្រុមហ៊ុននៅមានការងារធ្វើធម្មតា ហើយបានជ្រើសរើសកម្មករនិយោជិតថ្មី ជាបន្តបន្ទាប់ ។
- ប្រធានសហជីពបញ្ជាក់ថា កម្មករនិយោជិតទាំង ០៨ នាក់ ដែលក្រុមហ៊ុនបានបញ្ឈប់នេះ សុទ្ធតែជាបេក្ខជន ឈរឈ្មោះបោះឆ្នោតហើយត្រូវក្រុមហ៊ុនបញ្ឈប់តាមកាលបរិច្ឆេទដូចខាងក្រោម៖

| ល.រ | ឈ្មោះ | អត្តលេខ | ផ្នែក | ថ្ងៃ ខែ ឆ្នាំ ចូលបំរើការងារ | ថ្ងៃ ខែ ឆ្នាំ បញ្ឈប់ពីការងារ | តួនាទី |
|---|---|---|---|---|---|---|
| ១ | ម៉ាត់ ស៊ុបពីអ៊ី | ០១៤៩ | ស្រេះ-ដេរ | ២៧-មេសា ២០០៧ | ២២.មិថុនា.២០០៧ | ប្រធានសហជីព |
| ២ | សឿន វណ្ណារី | ០១៩១ | ស្រេះ | ១៧ ឧសភា ២០០៧ | ២៦.មិថុនា.២០០៧ | អនុប្រធានសហជីព |
| ៣ | ចាន់ សាន់ | ០៣១៦ | គូស | ២០ មេសា ២០០៧ | ២៦.មិថុនា.២០០៧ | លេខាធិការ |
| ៤ | វ៉ែន លក្ខណា | ០១៦៦ | ដេរ | ០៣ ឧសភា ២០០៧ | ២៦.មិថុនា.២០០៧ | ហិរញ្ញិក |
| ៥ | ជិន ស្រីនាង | ០១៦៥ | ដេរ | ០៣ ឧសភា ២០០៧ | ២៦.មិថុនា.២០០៧ | ទីប្រឹក្សាទី២ |
| ៦ | ហេត ម៉ារី | ០០៥៥ | ដេរ | ២៣ មេសា ២០០៧ | ២៦.មិថុនា.២០០៧ | ទីប្រឹក្សាទី១ |
| ៧ | ថៃ ប៊ុនធឿន | ០១០០ | ដេរ | - | មិនទាន់បញ្ឈប់ | ទីប្រឹក្សាទី៣ |
| ៨ | ឆាន ហៃ | ១០៥៥ | ដេរ | - | ២៦.មិថុនា.២០០៧ | ទីប្រឹក្សាទី៥ |
| ៩ | ស៊ុន សោភណ្ឌ័ | ០១៦១ | ដេរ | ០៣ ឧសភា ២០០៧ | ២៦.មិថុនា.២០០៧ | ទីប្រឹក្សាទី៤ |

- ប្រធានសហជីពបញ្ជាក់ថា កម្មករនិយោជិតទាំងអស់បានបើកប្រាក់បំណាច់ការងាររួចអស់ហើយៗ នៅសល់តែ ចាន់ សាន់ ទេដែលមិនទាន់បើក។ សហជីពបញ្ជាក់ថាកម្មករនិយោជិតភាគច្រើនរកការងារធ្វើកន្លែងផ្សេងបានហើយ នៅសល់តែរូបលោក និង ឈ្មោះ ចាន់ សាន់ ប៉ុណ្ណោះ។ ប៉ុន្តែ ពួកគេចង់ត្រឡប់មករោងចក្រដើមវិញ ព្រោះនៅជិតផ្ទះ។ ប្រធានសហជីពបញ្ជាក់ថា កម្មករឈ្មោះ ថៃ ប៊ុនធឿន ត្រូវក្រុមហ៊ុនបញ្ឈប់ពីការងារ ប៉ុន្តែក្រោយមក ក្រុមហ៊ុនបានទទួលយកគាត់ចូលធ្វើការវិញ ដោយសារតែគាត់បានលាឈប់ពីសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ប៉ាយ ហឺ។
- នៅក្នុងសវនាការប្រធានសហជីពបានស្នើសុំឱ្យក្រុមហ៊ុនទទួលយកពួកគេទាំង ០៨នាក់ ចូលធ្វើការវិញ ដោយសារការបញ្ឈប់ពួកគេនេះមានការរើសអើងសហជីព ព្រោះពួកគេសុទ្ធតែជាបេក្ខជនឈរឈ្មោះសហជីព និងជាថ្នាក់ដឹកនាំសហជីពដែលជាប់ឆ្នោត។
- តំណាងក្រុមហ៊ុនអវត្តមាននៅក្នុងសវនាការនេះ ដោយគ្មានមូលហេតុ ហើយក៏មិនបានផ្តល់ភស្តុតាងណាមួយឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាដែរ។

## ហេតុផលនៃសេចក្តីសម្រេច

មុននឹងធ្វើការបកស្រាយលើចំណុចវិវាទនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថាតើអាជ្ញាកណ្តាលអាចបើកសវនាការដោយកំបាំងមុខនិយោជកដែរ ឬទេ?

ប្រការ ២១ នៃប្រកាស លេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ *ចែងថា " ក្នុងករណី ភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយតែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់ ។ "*

ទាក់ទងនឹងខ្លឹមសារនៃ ប្រការ ២១ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ នៅក្នុងសំណុំរឿងមុនៗ នៅពេលដែលភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវ ហើយតែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសំរេចបន្តដំណើរការរបស់ខ្លួនដោយអវត្តមានរបស់ភាគីនោះ ។ ជាក់ស្តែងដូចជានៅក្នុងសំណុំរឿងលេខ ៥៣/០៤-គួង ហុង និង សំណុំរឿងលេខ ៦៣/០៤-សាញ វ៉ែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសំរេចបន្តដំណើរការរបស់ខ្លួនដោយអវត្តមានរបស់ភាគីនិយោជក ។ (សូមមើលសេចក្តីបង្គាប់លេខ ៥៣/០៤-គួង ហុង ៦៣/០៤-សាញ វ៉ែល) ។

នៅក្នុងរឿងនេះ មានតែប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន ប៉ាយ ហ៊ី និងសម្ព័ន្ធសហជីពសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាទេ ដែលចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ប៉ុន្តែ ភាគីនិយោជកមិនបានចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ហើយក៏មិនបានបង្ហាញមូលហេតុត្រឹមត្រូវអំពីការមិនចូលរួមនេះដែរ ។

ដូច្នេះដើម្បីឱ្យស្របនឹងសេចក្តីបង្គាប់ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿង លេខ ១៤៨/០៧ សំរេចបន្តដំណើរការរបស់ខ្លួនដោយធ្វើការបើកសវនាការដោយកំបាំងមុខភាគីនិយោជក និង ចំពោះមុខភាគីកម្មករ និយោជិតដើម្បីវិនិច្ឆ័យលើសំណុំរឿងដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ដោយផ្អែកលើភស្តុតាង និង ការបកស្រាយបំភ្លឺរបស់ប្រធានសហជីពនៅក្នុងសវនាការ ។

**ចំណុចបញ្ហាវិវាទទី១: កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកបេក្ខជនឈរឈ្មោះថ្នាក់ដឹកនាំសហជីពចំនួន ០៨នាក់ចូលធ្វើការវិញគឺ ១- លោក ម៉ាត់ ស៊ុបពីអ៊ី ២- អ្នកស្រី សឿន វណ្ណារី ៣-លោកស្រី ចាន់ សាន់ ៤-កញ្ញា វ៉ែន លក្ខណា ៥-កញ្ញា ជិន ស្រីនាង ៦-កញ្ញា ហេត ម៉ារី ៧-លោកស្រី នាន ហៃ ៨-លោកស្រី ស៊ុន សោភណ្ឌ័**

ក្នុងករណីនេះ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកបេក្ខជនឈរឈ្មោះថ្នាក់ដឹកនាំសហជីពចំនួន ០៨នាក់ចូលធ្វើការវិញ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើករណីនេះដូចខាងក្រោម:

*១. តើការបញ្ឈប់កម្មករនិយោជិតទាំង ៨ នាក់នេះ មានការរើសអើងសហជីពដែរ ឬទេ?*

*២. តើនិយោជកបានគោរពតាមច្បាប់ដែរ ឬទេ នៅពេលបញ្ឈប់កម្មករនិយោជិតទាំង ៨នាក់នេះ?*

THE ARBITRATION COUNCIL

**១.តើការបញ្ឈប់កម្មករនិយោជិតទាំង ៨ នាក់នេះ មានការរើសអើងសហជីពដែរ ឬទេ?**

កថាខ័ណ្ឌទី១ នៃមាត្រា២៦៦ នៃច្បាប់ស្តីពីការងារបានចែងថា *"ដោយគ្មានការប្រកាន់អ្វីទាំងអស់ និង ដោយមិនចាំបាច់មានការអនុញ្ញាតជាមុន កម្មករនិយោជិត និងនិយោជកមានសិទ្ធិបង្កើតអង្គការវិជ្ជាជីវៈតាមការជ្រើសរើសរបស់ខ្លួន ក្នុងគោលបំណងសំរាប់តែការសិក្សាលើកតំកើងផលប្រយោជន៍ និងការការពារសិទ្ធិក៏ដូចជាផលប្រយោជន៍ផ្នែកស្មារតី និងសំភារៈជាសមូហភាព និងជាឯកត្តជនចំពោះបុគ្គលដែលលក្ខន្តិកៈរបស់អង្គការនោះដែលបានកំណត់ ។."*

មាត្រា ១២ នៃច្បាប់ស្តីពីការងារបានចែងថា *" ..... គ្មាននិយោជកណាម្នាក់អាចយកបញ្ហា: .......ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីជាលេសធ្វើសេចក្តីសំរេចអំពីៈ ការជួល ...... ឬការផ្តាច់កិច្ចសន្យាការងារ .... ។."*

មាត្រា ២៧៩ នៃច្បាប់ស្តីពីការងារចែងថា *" ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូបមិនអោយយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមក្នុងសកម្មភាពរបស់សហជីពនៃកម្មករនិយោជិតដើម្បីធ្វើការសំរេចក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ..... និងការបណ្តេញចេញ ។"*

ទាក់ទងនឹងខ្លឹមសារនៃមាត្រា១២ និងមាត្រា២៧៩នៃច្បាប់ស្តីពីការងារ ខាងលើ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិតចូលធ្វើ ការវិញដោយសារការបញ្ឈប់កម្មករនិយោជិតទាំងអស់នោះមានការរើសអើងសហជីព ដែលបំពាននឹងមាត្រា ១២ និង២៧៩នៃច្បាប់ស្តីពីការងារ ដែលហាមឃាត់និយោជកមិនឱ្យយកហេតុផលនៃការចូលជាសមាជិកសហជីព ឬ ការធ្វើសកម្មភាពសហជីព ដើម្បីជួល ឬដាក់វិន័យ ឬ ផ្តាច់កិច្ចសន្យាការងាររបស់កម្មករនិយោជិតរបស់ខ្លួនឡើយ ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *២៨/០៧-ដេ ហ្វាង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៣ និង លេខ១២៣/០៧ -អ៊ីប្តាមេន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១*) ។

ទាក់ទងនឹងការចោទប្រកាន់និយោជកមានការរើសអើងសហជីព នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាងក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៥០/០៦-អេវើហ្គ្រីន ចំណុចវិវាទទី១ លេខ១១២/០៦ -វីវើរិច ចំណុចវិវាទទី១ និង លេខ០១/០៧-ស៊ុខ ព្រីម ចំណុច វិវាទទី១ ។)

ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាងដែលពាក់ពន្ធ័ទៅនឹងសំណុំរឿង ដើម្បីកំណត់ថាមានការរើសអើងសហជីពកើតមានឡើងទាក់ទងនឹងការបញ្ឈប់កម្មករនិយោជិតដែរ ឬទេ។ (សូមមើល សេចក្តីបង្គាប់លេខ ០៣/០៣-តុង ប្តា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១០/០៣ ហ្សាក់ស៊ីនតិច ហេតុផលនៃ

សេចក្តីសម្រេច ចំណុចវិវាទទី៤ ១៩/០៤-ក្បាល កោះ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និង *១៧/០៧ - ឆាម ចិចថាយ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១)* ។

នៅក្នុងករណីនេះ នៅក្នុងសវនាការប្រធានសហជីពបានបញ្ជាក់ថា សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានប្រគល់លិខិតជូនដំណឹងអំពីការរៀបចំបង្កើតសហជីពថ្មី ប្រចាំរោងចក្រ ប៉ាយ ហ៊ឺ លេខ ០៥៦/០៧ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ ទៅឱ្យនិយោជក ហើយសន្តិសុខរបស់ក្រុមហ៊ុនជាអ្នកចុះហត្ថលេខាទទួលយក។ ក្រោយ ពីការជូនដំណឹងនេះ នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៧ លោក ម៉ាត់ ស៊ុបពីអ៊ី ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារដោយគ្មានមូលហេតុ ហើយប៉ុន្មានថ្ងៃក្រោយមក គឺនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ កម្មករនិយោជិតចំនួន ០៧ នាក់ ទៀតក៏ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារដោយគ្មានមូលហេតុដែរ។ បន្ថែមពីលើនេះទៀត តាមការអះអាងរបស់ប្រធានសហជីព បញ្ជាក់ថា កម្មករឈ្មោះ ថៃ ប៊ុនធឿន ក៏ត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារដែរ ប៉ុន្តែក្រោយមកត្រូវក្រុមហ៊ុនទទួលយកចូលធ្វើការវិញ ដោយសារតែគាត់លាឈប់ពីសហជីព។

បន្ថែមពីលើនេះទៀត លទ្ធផលនៃការបោះឆ្នោត នៅក្នុងរោងចក្រ ប៉ាយ ហ៊ឺ បញ្ជាក់ថា លោក ម៉ាត់ ស៊ុបពីអ៊ី ជាប្រធានសហជីព អ្នកស្រី សឿន វណ្ណារី និង អ្នកស្រី ចាន់ សាន់ ជាប់ជាលេខាសហជីព។ ហើយក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានចេញលិខិតលេខ១៤០ កប ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៧ និងវិញ្ញាបនប័ត្រចុះបញ្ជិកា នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៧ ដែលបញ្ជាក់ពីការទទួលស្គាល់ ថ្នាក់ដឹកនាំសហជីពទាំងបីនាក់នៅក្នុងរោងចក្រ ប៉ាយ ហ៊ឺ ។ ចំណែកឯកម្មករផ្សេងទៀត គឺជាបេក្ខជនដែលឈរឈ្មោះបោះឆ្នោត និងជាប់ជាទីប្រឹក្សាសហជីព។

ផ្អែកលើភស្តុតាង ដែលបំភ្លឺដោយសហជីពនៅក្នុងសវនាការ និងភស្តុតាងដែលសហជីពប្រគល់មកក្រុមប្រឹក្សាអាជ្ញាកណ្តាលដូចការបកស្រាយខាងលើ ព្រមទាំងការខកខានរបស់ភាគីនិយោជកមិនចូលរួមក្នុងសវនាការ និងមិនបានផ្តល់ភស្តុតាង ដើម្បីដោះបន្ទុកការចោទប្រកាន់របស់កម្មករនិយោជិត ទាក់ទងនឹងការរើសអើងសហជីព។ សរុបសេចក្តីមកក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថាការបញ្ឈប់កម្មករនិយោជិតទាំង ០៨នាក់នេះពាក់ព័ន្ធនឹងការរើសអើងសហជីព ព្រោះការបញ្ឈប់នេះកើតមានក្រោយពេលដែលសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាបានជូនដំណឹងទៅក្រុមហ៊ុនអំពីការបោះឆ្នោត និងអំពីលទ្ធផលនៃការបោះឆ្នោតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃ រោងចក្រ ប៉ាយ ហ៊ឺ។

**២. តើនិយោជកបានគោរពតាមច្បាប់ដែរ ឬទេ នៅពេលបញ្ឈប់កម្មករនិយោជិតទាំង ០៨នាក់នេះ?**

កថាខ័ណ្ឌទី១ នៃមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើបានលុះណាតែមានការយល់ព្រមពីអធិការការងារ។ ...វិធានការការពារទាំងឡាយដូចគ្នានេះ ត្រូវអនុវត្តចំពោះអតីតប្រតិភូបុគ្គលិក..... ។....ដែរ ។"*

កថាខ័ណ្ឌទី៣ ប្រការ៣ នៃប្រកាសលេខ ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា " *កម្មករនិយោជិតទាំងអស់ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពទទួលបាននូវការការពារ ចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល ៤៥ ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបញ្ចប់ ក្នុងរយៈពេល ៤៥ ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណើងទៅនិយោជកអំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ ។ និយោជកត្រូវអនុវត្តបទបញ្ញត្តិនេះនៅរាល់ពេលបោះឆ្នោត ជ្រើសរើសថ្នាក់ដឹកនាំសហជីព ។* "

បន្ថែមលើសពីនេះទៀត កថាខណ្ឌទី១ ប្រការ៤ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា "*ចាប់តាំងពីពេលដាក់ពាក្យចុះបញ្ជីកាសហជីពកម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះក្នុងពេលកំពុងស្នើសុំចុះបញ្ជីកា ត្រូវបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេលរហូតដល់ ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះបញ្ជីកាសហជីព ។*"

យោងតាមខ្លឹមសារនៃ កថាខ័ណ្ឌទី៣ ប្រការ៣ និង កថាខ័ណ្ឌទី១ ប្រការ៤ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ថ្នាក់ដឹកនាំសហជីព កម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីព ក្នុងអំឡុងពេលសុំចុះបញ្ជីកាសហជីព ត្រូវបានទទួលការការពារពីការបញ្ឈប់ពីការងារ ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយ ប្រការ៣ និងប្រការ៤ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ថា កម្មករនិយោជិតអាចទទួលបានការការពារពិសេស ដរាបណា *(១) កម្មករនិយោជិតជាប្រភេទកម្មករដែលទទួលបានការការពារពិសេស (២) ការបញ្ឈប់ត្រូវធ្វើឡើងក្នុងអំឡុងពេលដែលត្រូវទទួលបានការការពារពិសេស និង (៣) សហជីពត្រូវជូនដំណើងទៅនិយោជកអំពីបេក្ខភាពកម្មករដែលត្រូវទទួលការការពារតាមមធ្យោបាយទាំងអស់ដែលទុកជាបានការ។* (សូមមើលសេចក្តីបង្គាប់សំណុំរឿងលេខ *០៧/០៦-ដាយ យ៉ាង ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១. និង ០៩/០៦-ប្រ៊ែនដ៍ ដាយ អឹម៉ិន ស៊ីធី ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា សហជីពបានបំពេញនូវលក្ខខណ្ឌទាំង ៣ ខាងលើ:

លក្ខខណ្ឌទី១ ត្រូវបានបំពេញ ព្រោះក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លោក ម៉ាត់ ស៊ុបពីអ៊ី អ្នកស្រី សឿន វណ្ណារី និង អ្នកស្រី ចាន់ សាន់ ជាថ្នាក់ដឹកនាំសហជីព តាមកថាខ័ណ្ឌទី៣ ប្រការ៣ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១។ ចំណែកឯ កញ្ញា ជិន ស្រីនាង លោកស្រី សាន ហេ. ហោត ម៉ារី. វ៉ែន លក្ខណា និង លោកស្រី ស៊ុន សោភណ្ឌ័ ជាស្ថាបនិក ចាប់តាំងពីពេលសុំចុះបញ្ជីកាសហជីព ឬកម្មករ

និយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកក្នុងកំឡុងពេលសុំចុះបញ្ជិកាសហជីព តាមកថាខ័ណ្ឌទី១ប្រការ៤នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ។

លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ដោយសារតែនិយោជកបានបញ្ឈប់ពួកគាត់ទាំង ០៨នាក់ នៅក្នុងអំឡុងពេលដែលត្រូវទទួលបានការការពារពិសេស។ មានន័យថា សហជីពនេះបាន ប្រគល់លិខិតជូនដំណឹងអំពីការរៀបចំបោះឆ្នោតបង្កើតសហជីពថ្មីលេខ ០៥៦/០៧ ស.ប.ក.ក ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ ទៅឱ្យនិយោជក ហើយសន្តិសុខរបស់ក្រុមហ៊ុនជាអ្នកចុះហត្ថលេខាទទួលយក។ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៧ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានរៀបចំបោះឆ្នោតតាមនីតិវិធី។ ហើយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានជូនដំណឹង ទៅក្រុមហ៊ុនអំពីលទ្ធផលនៃការបោះឆ្នោត។ ហើយកម្មករនិយោជិតទាំង ០៨ នាក់នេះ ត្រូវបញ្ឈប់ពីការងារ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ និងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០០៧ ដែលជារយៈពេលដែលកម្មករបាននូវការការពារ ចំពោះការបញ្ឈប់ពីការងារ តាមខ្លឹមសារនៃប្រការ៣ និង ប្រការ៤ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ។ (សូមមើលសេចក្តីបង្គាប់លេខ *០៧/០៦- ដាយ យ៉ាំង ហេតុផលនៃសេចក្តី សម្រេច ចំណុចវិវាទទី១*)។

លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ ដោយសារតែសហជីពបានជូនដំណឹងទៅនិយោជកអំពីបេក្ខភាពកម្មករដែលត្រូវទទួលបានការការពារតាមមធ្យោបាយទាំងអស់ដែលទុកជាបានការ។ មានន័យថា យោងតាមសារណារបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងការឆ្លើយបំភ្លឺរបស់ប្រធានសហជីពនៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពបានជូនដំណឹងទៅនិយោជកអំពីលទ្ធផលនៃការបោះឆ្នោតនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៧ ដែលមានលោក ម៉ាត់ ស៊ុបពីអ៊ី ជាប់ជាប្រធានសហជីព អ្នកស្រី សឿន វណ្ណារីជាប់ជាអនុប្រធាន និង អ្នកស្រី ចាន់សាន់ ជាលេខាធិការនី ព្រមទាំងកម្មករចំនួន ០៦នាក់ ទៀត ដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយដែលក្នុងនោះមានកម្មករ ០៥នាក់ ( កញ្ញា ជិន ស្រីនាង. លោកស្រី អាន ហៃ. ហេត ម៉ារី .វ៉ែន លក្ខណា និង លោកស្រី ស៊ុន សោភណ្ឌ័)ដែលក្រុមហ៊ុនបានបញ្ឈប់ពីការងារ នៅក្នុងសំណុំរឿងនេះ ។ បន្ថែមពីលើនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញភស្តុតាងណាដែលបញ្ជាក់ថា និយោជកមិនបានទទួលដំណឹងនេះទេ ព្រោះនិយោជកមិនបានចូលរួមសវនាការ និងមិនបានផ្តល់ភស្តុតាងដើម្បីដោះបន្ទុក។

ផ្អែកលើការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ០៨ នាក់បានបំពេញលក្ខណៈវិនិច្ឆ័យ ក្នុងការទទួលបានការការពារពីការបញ្ឈប់ពីការងារ ដូចបានកំណត់ក្នុងកថាខ័ណ្ឌទី៣ ប្រការ៣ និង កថាខ័ណ្ឌទី១ ប្រការ៤ នៃប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ខាងលើ ។ ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថានិយោជកត្រូវមានការយល់ព្រមពីអធិការការងារដើម្បីបញ្ឈប់កម្មករនិយោជិតទាំង ០៨ នាក់ នេះព្រោះពួកគេទទួលបានការការពារពិសេសក្នុងពេលចុះបញ្ជិកាសហជីព។ បន្ថែម

THE ARBITRATION COUNCIL

ពីលើនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏រកមិនឃើញភស្តុតាងណាដែលបញ្ជាក់ថា និយោជកបានទទួលការអនុញ្ញាតិពីអធិការការងារទេ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកបានបញ្ឈប់កម្មករនិយោជិតទាំង ០៨ នាក់នេះ ពីការងារដោយសារការរើសអើងសហជីព ដែលមិនស្របតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ។ លើសពីនេះទៀត និយោជកមិនបានគោរពតាមច្បាប់ស្តីពីការងារនៅពេលបញ្ឈប់កម្មករនិយោជិតទេ។

ម្យ៉ាងវិញទៀត ប្រការ ៣៤ នៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ចែងថា"...ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេច.. ដោយរួមទាំងការៈ ក-បញ្ជាឱ្យទទួលយកកម្មករនិយោជិតដែលបានបណ្តេញចេញឱ្យចូលធ្វើការវិញ នៅក្នុងតំណែងចាស់ ឬតំណែងសមរម្យណាមួយ...។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបញ្ជាឱ្យនិយោជកទទួលយកកម្មករនិយោជិតទាំង ០៨នាក់ដែលជាថ្នាក់ដឹកនាំសហជីព និង ទីប្រឹក្សាសហជីពចូលធ្វើការវិញ។ (សូមមើលសេចក្តីបង្គាប់ *០២/០៤- សណ្ឋាគារកាំបូឌីយ៉ាណា ហេតុផលនៃសេចក្តីសម្រេច ចំណុច វិវាទទី១ ១៧/០៤-ឈោ វីយូ ចំណុចបញ្ហាទី ១ និង ១៩/០៤-ក្បាលកោះ២ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១ និង ១៧/០៧ - ឆាម ចិចថាយ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ១)* ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ :

## <u>សម្រេច និង បង្គាប់</u>

បង្គាប់ឱ្យនិយោជក ទទួលយកកម្មករនិយោជិតទាំង ០៨នាក់ដែលជាថ្នាក់ដឹកនាំសហជីព និងទីប្រឹក្សាសហជីពចូលធ្វើការវិញ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ថ្ងៃបើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

THE ARBITRATION COUNCIL

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ហែម ហួណារិទ្ធិ**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ស៊ុន គីមស៊ាន**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------